00916639

E285/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 31 / 05 / 2013
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH Arun

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣

**ជូនចំពោះ៖** ភាគីនៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក /លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន៨៧(៤)នៃវិធានផ្ទៃក្នុងស្នើសុំដាក់ភស្តុតាងថ្មី ពាក់ព័ន្ធនឹងព្យសនកម្មលើជនរងគ្រោះ (ឯកសារ E285)

១. អង្គជំនុំជម្រះបានទទួលសំណើមួយពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវភស្តុតាងថ្មីដែលមានឯកសារចំនួន ០៦ ពាក់ព័ន្ធនឹងបញ្ហាសុខភាពផ្លូវចិត្តដែលអ្នករួចជីវិតពីរបបខ្មែរក្រហមកំពុងជួបប្រទះ (ឯកសារE285) ។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងថ្មីនានា ដែលខ្លួនចាត់ទុកថាអាចនាំទៅដល់ការបញ្ជាក់ការពិត នៅពេលដែលភស្តុតាងនោះបំពេញបទដ្ឋាន *ការបញ្ជាក់បឋម* នៃភាពពាក់ព័ន្ធ ភាពអាចជឿជាក់បាន និងយថាភាព ដែលត្រូវបានតម្រូវដោយវិធាន ៨៧(៣)។ ជាទូទៅ ភាគីស្នើសុំត្រូវធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថាភស្តុតាងថ្មីដែលខ្លួនស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះពុំអាចរកបាននៅមុនពេលបើកសវនាការ ឬពុំអាចត្រូវបានរកឃើញដោយការយកចិត្តទុកដាក់ត្រឹមត្រូវ។ ទោះជាយ៉ាងនេះក្តី

00916640

E285/1

ក្នុងករណីខ្លះ អង្គជំនុំជម្រះបានទទួលយកភស្តុតាងដែលពុំបំពេញលក្ខខណ្ឌនេះផងដែរ ដូចជានៅក្នុងករណីដែលភស្តុតាងទាក់ទងយ៉ាងជិតស្និទជាមួយនឹងសម្ភារៈដែលមាននៅចំពោះមុខអង្គជំនុំជម្រះ និងក្នុងករណីដែលផលប្រយោជន៍នៃយុត្តិធម៌តម្រូវឱ្យមានការវាយតម្លៃប្រភពទាំងនេះរួមគ្នា នៅពេលដែលភស្តុតាងដែលបានស្នើសុំដាក់នេះជាភស្តុតាងដោះបន្ទុក និងត្រូវការវាយតម្លៃដើម្បីបញ្ចៀសការខុសឆ្គង ឬនៅពេលដែលភាគីដទៃទៀតពុំជំទាស់ទៅនឹងភស្តុតាងនេះ។ (*សូមមើល ឧទាហរណ៍* ឯកសារ E190, កថាខណ្ឌ ១៩-២១ និងឯកសារ E172/24/5/1)។

៣. ឯកសារដែលត្រូវបានស្នើសុំដាក់ E285.1.1 (សៀវភៅកែសម្រួលរបស់ van Schaack និងបុគ្គលដទៃទៀត ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងខែ កញ្ញា ឆ្នាំ ២០១១), ឯកសារ E285.1.2 (អត្ថបទមួយរបស់ Wong និងបុគ្គលដទៃទៀត ដែលត្រូវបានបោះពុម្ពផ្សាយតាមប្រព័ន្ធអ៊ិនធឺណែតកាលពីខែ កញ្ញា ឆ្នាំ ២០១០) និងឯកសារ E285.1.3 (អត្ថបទមួយរបស់ Marshall និងបុគ្គលដទៃទៀត ដែលត្រូវបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០០៥) មាននៅមុនពេលនៃការបើកសវនាការនៅក្នុងខែវិច្ឆិកា ឆ្នាំ ២០១១។ បើទោះបីជាឯកសារ E285.1.4 (អត្ថបទមួយរបស់ Stammel និងបុគ្គលដទៃទៀត) និងឯកសារ E285.1.5 (សេចក្ដីអត្ថាធិប្បាយមួយរបស់គណៈកម្មាធិការប្រឆាំងនឹងអំពើទារុណកម្ម) ពុំអាចរកបាននៅមុនពេលបើកសវនាការក៏ដោយ ក៏ឯកសារទាំងនេះត្រូវបានបោះពុម្ពផ្សាយនៅក្នុងខែ មករា ឆ្នាំ ២០១៣ និងខែ ធ្នូ ឆ្នាំ ២០១២ ដាច់ដោយឡែកពីគ្នា។ ដោយពុំមានការពន្យល់បន្ថែមអំពីមូលហេតុដែលឯកសារទាំងនេះពុំអាចត្រូវបានរកឃើញ ដោយមានកិច្ចខិតខំត្រឹមត្រូវ ឬត្រូវបានបង្ហាញឱ្យបានមុននេះ សហមេធាវីនាំមុខពុំបានបំពេញលក្ខខណ្ឌតម្រូវតឹងរ៉ឹងនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងឡើយ។ យ៉ាងណាមិញ ឯកសារទាំងនេះត្រូវបានបង្ហាញនៅមុនពេលសវនាការលើព្យសនកម្មជនរងគ្រោះ និងពុំត្រូវបានភាគីដទៃទៀតជំទាស់ឡើយ។

៤. អង្គជំនុំជម្រះកត់សម្គាល់ឃើញទៀតថាផ្នែកនានានៃឯកសារ E285.1.1 និងឯកសារ E285.1.4 ត្រូវបាននិពន្ធរួមដោយអ្នកជំនាញដែលមានរហស្សនាម TCE-12 និងទំនងជាទាក់ទងនឹងសក្ខីកម្មរបស់គាត់នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ ខាងមុខ។ ឯកសារ E285.1.2 និងឯកសារ E285.1.3 ទាក់ទងនឹងស្ថានភាពសុខភាពរបស់ជនភៀសខ្លួនកម្ពុជាដែលបានតាំង

លំនៅជាថ្មីនៅ ០២ ទសវត្សរ៍ក្រោយ និងអាចពាក់ព័ន្ធទៅនឹងសក្ខីកម្មនាពេលខាងមុខរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-4 ដែលរស់នៅឯសហរដ្ឋអាមេរិក និងត្រូវបានកំណត់កាលបរិច្ឆេទដើម្បីផ្ដល់សក្ខីកម្មនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១៣។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាជាផលប្រយោជន៍នៃយុត្តិធម៌ដែលត្រូវវាយតម្លៃភស្តុតាងនេះព្រមគ្នា។ ឯកសារ E285.1.5 ពិភាក្សាអំពីសិទ្ធិរបស់ជនរងគ្រោះពីការធ្វើទារុណកម្មក្នុងការទទួលបានសំណង ហេតុដូច្នេះ វាជាឯកសារពាក់ព័ន្ធជាសំខាន់ទៅនឹងសំណង។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះឯកភាពតាមសំណើរបស់សហមេធាវីនាំមុខដែលស្នើសុំដាក់ឯកសារ E285.1.1 រហូតដល់ឯកសារ E285.1.5 នៅក្នុងសំណុំរឿង។ អង្គជំនុំជម្រះនឹងស្ដាប់ការជំទាស់ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ប្រសិនបើមានទៅនឹងភាពអាចទទួលយកបាននៃឯកសារទាំងនេះ ប្រសិនបើសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំដាក់ភស្តុតាងនេះនៅចំពោះមុខអង្គជំនុំជម្រះ។

៥. ពាក់ព័ន្ធនឹងឯកសារ E285.1.6 (ឯកសារបោះពុម្ពផ្សាយរបស់ យឹម សុធារី ស្ដីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលវិភាគអំពីការប៉ះទង្គិចផ្លូវចិត្តរបស់ស្ត្រីចំនួន ០៨ រូប ដែលបានឆ្លងកាត់ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបខ្មែរក្រហម)។ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពុំបានបង្ហាញពីភាពពាក់ព័ន្ធនៃឯកសារនេះទៅនឹងសំណុំរឿង ០០២/០១ នោះឡើយ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះបដិសេធសំណើស្នើសុំដាក់ឯកសារនេះនៅក្នុងសំណុំរឿង។

៦. លើកលែងតែឯកសារ E285.1.5 ដែលមានជាភាសាបារាំងផងដែរនោះ ឯកសារទាំងអស់នាពេលបច្ចុប្បន្នមានតែជាភាសាអង់គ្លេសប៉ុណ្ណោះ។ ការទទួលយកឯកសារទាំងនេះនៅចំពោះមុខអង្គជំនុំជម្រះ គឺវាអាស្រ័យទៅលើការមានឯកសារបកប្រែទាន់ពេលវេលា ហើយចំណែកការប្រើប្រាស់ឯកសារទាំងនោះក៏វាអាស្រ័យទៅលើការមានឯកសារទាំងនោះទាន់ពេលវេលាយ៉ាងហោចណាស់ជាភាសាខ្មែរដែរ។

៧. នេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងឯកសារ E285។